ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ១០៥ /២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃជំនួបរវាងរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយតំណាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងកិច្ចប្រជុំគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែ

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៦ តបតាមការអញ្ជើញរបស់**លោកជំទាវ ម៉ា តេរ៉េសា ភី ឡាហ្សារ៉ូ** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋហ្វីលីពីន និងជាប្រធានអាស៊ាន **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជំនួបរវាងរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយតំណាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (AICHR) និងកិច្ចប្រជុំគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែ (SEANWFZ)។

នៅក្នុងជំនួបជាមួយតំណាង AICHR រដ្ឋមន្ត្រីការបរទេសអាស៊ានបានកត់សម្គាល់នូវរបាយការណ៍ប្រចាំឆ្នាំ២០២៦ របស់ AICHR ព្រមទាំងបានស្វាគមន៍វឌ្ឍនភាពដែលសម្រេចបានក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស នៅក្នុងតំបន់។ រដ្ឋមន្ត្រីការបរទេសអាស៊ានបានលើកទឹកចិត្តឱ្យ AICHR បន្តអនុវត្តកម្មវិធីអាទិភាពរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងផ្តោតលើលទ្ធផល ស្របតាមផែនការការងារប្រាំឆ្នាំរបស់ AICHR (ឆ្នាំ២០២៦-២០៣០) និងដើម្បីគាំទ្រដល់ការអនុវត្តអាស៊ានឆ្នាំ២០៤៥៖ អនាគតរួមរបស់យើង។

នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីផលវិបាកនៃស្ថានភាពមនុស្សធម៌ និងសិទ្ធិមនុស្សដែលជនស៊ីវិលកម្ពុជាកំពុងប្រឈម ដោយសារបានក្លាយជាជនរងគ្រោះនៃជម្លោះព្រំដែន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានជម្រាបជូនអង្គប្រជុំថា ជនស៊ីវិលច្រើនជាង ២០.០០០នាក់បន្តរស់នៅក្នុងជម្រកបណ្តោះអាសន្ន ដោយមានកុមារជាច្រើននាក់មិនអាចចូលរៀនបាន ជនចាស់ជរា និងជនងាយរងគ្រោះផ្សេងទៀតខ្វះលទ្ធភាពទទួលបានការថែទាំចាំបាច់គ្រប់គ្រាន់ បើទោះបីរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងដើម្បីបន្ធូរបន្ថយការលំបាករបស់ពួកគេយ៉ាងណាក៏ដោយ។ ក្នុងន័យនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអំពាវនាវដល់សហការីអាស៊ានគាំទ្រការអំពាវនាវឱ្យពួកគាត់វិលត្រឡប់ទៅកាន់ផ្ទះសម្បែង និងរស់នៅដូចធម្មតាវិញ ដោយគ្មានការរារាំង ប្រកបដោយសុវត្ថិភាព និងភាពថ្លៃថ្នូរ។

កិច្ចប្រជុំគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែ បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តដ៏យូរអង្វែងឥតងាករេរបស់អាស៊ាន ក្នុងការរក្សាតំបន់អាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែ និងអាវុធប្រល័យលោកគ្រប់ប្រភេទ ស្របតាមធម្មនុញ្ញអាស៊ាន និងសន្ធិសញ្ញាស្តីពីតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែ (SEANWFZ Treaty)។ កិច្ចប្រជុំបានពិភាក្សាអំពីទិសដៅបន្តពាក់ព័ន្ធនឹងពិធីសារនៃសន្ធិសញ្ញា ព្រមទាំងបានផ្លាស់ប្តូរទស្សនៈអំពីការពង្រឹងកិច្ចសហប្រតិបត្តិការរវាងគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែ និងតំបន់គ្មានអាវុធនុយក្លេអ៊ែដទៃទៀត រួមទាំងជាមួយទីភ្នាក់ងារហាមឃាត់អាវុធនុយក្លេអ៊ែនៅ

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

អាម៉េរិកឡាទីននិងតំបន់ការ៉ាប៊ីន (OPANAL) និងតំបន់អាស៊ីកណ្ដាលគ្មានអាវុធនុយក្លេអ៊ែ (CANWFZ)។

នៅក្នុងបទអន្តរាគមន៍ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់ពីការកើនឡើងនៃសារៈសំខាន់របស់សន្ធិសញ្ញា SEANWFZ ដែលជាសសរស្ដម្ភដ៏សំខាន់នៃសន្តិភាព សន្តិសុខ និងស្ថិរភាព នៅអាស៊ីអាគ្នេយ៍ ស្របពេលដែលស្ថានការណ៍ភូមិសាស្ត្រនយោបាយសកលកាន់តែមានភាពស្មុគស្មាញ។ កម្ពុជាបានស្វាគមន៍នូវវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពនៃ SEANWFZ (ឆ្នាំ២០២៣-២០២៧) ជាពិសេសទៅលើសុវត្ថិភាព សន្តិសុខ និងវិធានការត្រួតពិនិត្យនុយក្លេអ៊ែ ការប្រើបច្ចេកវិទ្យានុយក្លេអ៊ែក្នុងគោលដៅសន្តិភាព ការកសាងសមត្ថភាព និងកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (IAEA)។ ក្នុងន័យនេះ កម្ពុជាបានស្វាគមន៍ចំពោះការត្រៀមខ្លួនរបស់ប្រទេសចិនក្នុងការចុះហត្ថលេខា និងការផ្ដល់សច្ចាប័នលើពិធីសារនៃសន្ធិសញ្ញា SEANWFZ ដោយគ្មានឧបសគ្គ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ក៏បានស្វាគមន៍ចំពោះការធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការរវាងអាស៊ាន ជាមួយ OPANAL និងជាមួយ CANWFZ ព្រមទាំងបានស្នើឱ្យមានពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការ តាមរយៈគំនិតផ្តួចផ្តើម និងផ្អែកលើគម្រោងជាក់ស្ដែង។

**<u>ជំនួបទ្វេភាគី៖</u>**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវ ម៉ា តេរ៉េសា ភី ឡាហ្សារ៉ូ** រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋហ្វីលីពីន បានសម្ដែងនូវការពេញចិត្តចំពោះសន្ទុះវិជ្ជមាននៃទំនាក់ទំនងទ្វេភាគី តាមរយៈការផ្លាស់ប្ដូរទស្សនកិច្ចកម្រិតខ្ពស់ និងកិច្ចសហប្រតិបត្តិការដែលរីកចម្រើននៅលើវិស័យផ្សេងៗ រួមមាន ការពារជាតិ និងសន្តិសុខ ពាណិជ្ជកម្ម និងវិនិយោគ កសិកម្ម ទេសចរណ៍ អប់រំ ការតភ្ជាប់ និងការផ្លាស់ប្ដូរប្រជាជននិងប្រជាជន។ រដ្ឋមន្ត្រីការបរទេសទាំងពីរក៏បានផ្លាស់ប្ដូរទស្សនៈលើការវិវត្តក្នុងតំបន់ និងអន្តរជាតិ រួមទាំងបញ្ហាដែលជាផលប្រយោជន៍រួម។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានកោតសរសើរចំពោះការគាំទ្រប្រកបដោយស្ថាបនា និងតួនាទីរបស់ហ្វីលីពីន ក្នុងការចូលរួមសម្របសម្រួលដោះស្រាយបញ្ហាព្រំដែនកម្ពុជា-ថៃ ដោយសន្តិវិធី និងដឹកនាំក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ក្នុងនាមជាប្រធានអាស៊ាន។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**ឯកឧត្តម បេនឌីតូ ជូស សាន់តូស ហ្រ្វេតាស** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការ នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ បានបញ្ជាក់ជាថ្មីអំពីចំណងមិត្តភាពដ៏ជិតស្និទ្ធ និងភាពរីកចម្រើននៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងទីម័រឡេស្តេ ព្រមទាំងបានសម្ដែងនូវការពេញចិត្តចំពោះសន្ទុះជាវិជ្ជមាននៃទំនាក់ទំនងទ្វេភាគី។ ភាគីទាំងពីរក៏បានឯកភាពគ្នាជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែស៊ីជម្រៅបន្ថែមទៀត នៅក្នុងវិស័យពាណិជ្ជកម្ម បរិវត្តកម្មឌីជីថល និងការកសាងសមត្ថភាព។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់សាជាថ្មីអំពីការគាំទ្រយ៉ាងពេញលេញរបស់កម្ពុជាចំពោះការត្រៀមលក្ខណៈរបស់ទីម័រឡេស្តេ ក្នុងការទទួលធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២៩ និងបានអះអាងជាថ្មីនូវការត្រៀមខ្លួនរួចជាស្រេចរបស់កម្ពុជា ក្នុងការចែករំលែកបទពិសោធរបស់ខ្លួន ដើម្បីធានាបាននូវភាពជោគជ័យនៃអាណត្តិជាប្រធានអាស៊ាននេះ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូន**ឯកឧត្តម បេនឌីតូ ជូស សាន់តូស ហ្រ្វេតាស** អំពីការវិវត្តថ្មីៗទាក់ទងនឹងស្ថានភាពព្រំដែនកម្ពុជា-ថៃផងដែរ។

ថ្ងៃអង្គារ ៧កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦